# សេចក្តីប្រកាសដាក់ពាក្យ:
# ជ្រើសរើសទីប្រឹក្សាផលិតខ្សែភាពយន្តឯកសារចំនួនបី

NGO-CEDAW

**គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាស៊ីដ (NGO-CEDAW) គឺជាអង្គការមិនរកប្រាក់ចំណេញ ដែលកំពុងធ្វើសកម្មភាពផ្តោតលើការជម្រុញអោយមានការគោរពសិទ្ធិមនុស្សរបស់ស្ត្រី។**

NGO-CEDAW ឧបត្ថម្ភក្នុងការបង្កើតខ្សែភាពយន្តឯកសារចំនួនបី ដើម្បីប្រើប្រាស់ជាមធ្យោបាយបង្កើនការយល់ដឹងជាសាធារណៈអំពីបញ្ហាដែលទាក់ទងនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។
គោលបំណងនៃការងារនេះគឺ ដើម្បីឱ្យប្រជាជនកម្ពុជាដែលមានទស្សនៈផ្សេងគ្នាអំពីអំពើហិង្សាក្នុងគ្រួសារជំនះទៅលើជំនឿរបស់ពួកគាត់អំពីតួនាទីយេនឌ័រ និងទទួលយកការប្រើប្រាស់ប្រពន្ធ័ច្បាប់ដើម្បីការពារស្ត្រី និងកុមារពីអំពើហិង្សាក្នុងគ្រួសារ។ NGO-CEDAW ក៏ប្រើប្រាស់ភាពយន្តឯកសារដែលផលិតឡើងទាំងនេះជាផ្នែកមួយនៃកិច្ចបន្តការខិតខំប្រឹងប្រែងតស៊ូមតិ ក្នុងការស្នើអោយមានការធ្វើវិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីផ្តល់ការការពារអោយកាន់តែប្រសើរឡើង លើការប្រើអំពើហឹង្សាទាក់ទងនឹងយេនឌ័រ ។ ភាពយន្តឯកសារខ្លីៗដែលបង្កើតឡើងនេះ នឹងត្រូវបានយកទៅចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងបញ្ចាំងជូនទស្សនិកជនក្រុមគោលដៅនានា។

## វិសាលភាពនៃការងារ:

NGO-CEDAW នឹងជួលទីប្រឹក្សា ១នាក់ ឬច្រើនជាងនេះ ដើម្បីបំពេញការងារដូចខាងក្រោមនេះ៖

១. បង្កើតគំនិតសម្រាប់ការប្រាស្រ័យទាក់ទងជាមួយសាធារណៈជន អំពីបញ្ហាអំពើហឹង្សាទាក់ទងនឹងយេន-ឌ័រ។
២. សរសេរប្លង់ (Script) ខ្សែភាពយន្តឯកសារ ថត និងកែសម្រួល
៣.ថតរូប និងវីឌីអូអំពីដំណើរការនៃការបង្កើតខ្សែភាពយន្ត ដែលនឹងត្រូវបានយកទៅប្រើប្រាស់ខាងក្នុងអង្គការ និងចែករំលែកជាមួយសាធារណជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និង/ឬផលិតជាឯកសារបោះពុម្ពផ្សេងៗទៀតសម្រាប់គោលបំណងផ្សព្វផ្សាយជាសារធារណៈ។

## ពេលវេលា

ការងារនេះត្រូវបំពេញអោយបានចប់ត្រឹមថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដើម្បីឱ្យខ្សែភាពយន្តឯកសារនេះ អាចយកប្រើប្រាស់ក្នុងអំឡុងយុទ្ធនាការរយៈពេល ១៦ ថ្ងៃប្រឆាំងនឹងអំពើហឹង្សាទាក់ទងនឹងយេនឌ័រ នៅចុងខែវិច្ឆិកា ឆ្នាំ ២០១៨។

## លក្ខខណ្ឌនៃការដាក់ពាក្យ:

ថ្ងៃផុតកំណត់នៃការដាក់ពាក្យ: ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០១៨ ។

ពាក្យសុំអាចធ្វើឡើងជាពីរភាសា គឺខ្មែរ ឬអង់គ្លេស។

អ្នកដាក់ពាក្យស្នើសុំម្នាក់ៗ អាចស្នើសុំបង្កើតភាពយន្តឯកសារតែមួយ ឯកសារពីរ ឬទាំងបី។

## ការដាក់ពាក្យសុំត្រូវមាន:

១. ជីវប្រវត្តិសង្ខេបរបស់អ្នកដាក់ពាក្យសុំ

២.ការពិពណ៌នាអំពីគំនិតនៃភាពយន្តឯកសារដែលស្នើឡើង និងពន្យល់ពីរបៀបដែលឯកសារផលិតឡើងនេះ បានលើកទឹកចិត្តឱ្យទស្សនិកជនប្រើប្រាស់ច្បាប់ក្នុងការបង្ការអំពើហឹង្សា។

៣. សំណើរសុំថវិកាមិនលើសពី ១៨០០ ដុល្លារសហរដ្ឋអាមេរិក សម្រាប់ឯកសារនិមួយៗ។ ចំដែលចំនួន នេះរួមបញ្ចូលទាំងពន្ធកាត់ទុក ១៥% និងការចំណាយផ្សេងៗទៀតសម្រាប់ការបង្កើតខ្សែភាពយន្ត។

៤. ការពន្យល់ខ្លីអំពីមូលហេតុដែលអ្នកចង់ចូលរួមនៅក្នុងគម្រោងនេះ។

សូមផ្ញើរពាក្យសុំរបស់អ្នកទៅកាន់អង្គការ NGO-CEDAW តាមរយៈអ៊ីម៉ែល ngocedaw.pnh@gmail.com ឬមកដាក់នៅការិយាល័យ NGO-CEDAW ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ខណ្ឌចំការមន សង្កាត់បឹងត្របែក រាជធានីភ្នំពេញ។